# ប្រអប់ ឧបករណ៍

នៅក្នុង ប្រអប់ ឧបករណ៍ នៃ នយោបាយ របស់ របប ក្រុងភ្នំពេញ មាន តែ ញញួរ ដែក ធំ បី ៈសម្លុត, សំពង និង គុក។ ជាឧបករណ៍ ប្រើ នៅក្នុង អគតិ ដើម្បី បំរើ អំណាច ផ្តាច់ការ តែមួយគត់។ ដូច្នេះ គម្រោង ច្បាប់ ដាក់ នគរ អោយ នៅក្នុងភាពអាសន្ន ដើម្បី ទប់ស្កាត់ ជម្ងឺ កូវិដ ១៩ គឺ ធ្វើឡើង នៅក្នុងអគតិ នេះឯង។ ពិតណាស់ហើយ នៅ ប្រទេស ប្រជាធិបតេយ្យធំៗ នៅលើ ពិភពលោក គេ បង្កើត ច្បាប់ពិសេស សំរាប់បង្ខាំង ប្រជាជន កុំអោយ ធ្វើ ចរាចរណ៍ តាមសេរី នៅពេលដែល មេរោគ កំពុង រីករាលដាល នៅក្នុង ប្រទេសនីមួយៗដើម្បី ជៀសវាង ការចម្លងរោគ ពី បុគ្គលមួយ ទៅ ជនដទៃទៀត, តែ នៅក្នុង ច្បាប់ពិសេសនោះ គេ ពុំបាន ឃាត់ឃាំងសេរីភាព ក្នុង ការបញ្ចេញមតិ ទាក់ទង នឹង បញ្ហា សុខភាពសាធារណៈនេះ ទោះបី ជា មតិ រិះគន់ធំៗ ដល់ ចំណាត់ការ របស់រដ្ឋាភិបាល យ៉ាងណាក៏ដោយ ព្រោះ មតិនេះឯង ជា វិភាគទានរួម សំរាប់ ស្វែងរក ប្រសិទ្ធិភាព នៅចំពោះមុខ ការគំរាមកំហែងរួម។ ត្រូវដឹងថា ស្រុកខ្មែរ ស្ថិត នៅក្រោម អំណាច ផ្តាច់ការ រួចទៅហើយ ដូច្នេះ ការប្រកាស ភាពអាសន្ន វា គ្មាន អ្វី ជាការប្តូរ របៀបដឹកនាំ នោះឡើយ ព្រោះ នៅក្នុង ប្រអប់ ឧបករណ៍ វា មានតែ ញញួរ បី ដដែល សំរាប់ វាយប្រហារ ប្រឆាំងនឹងសេរីភាព និង លទ្ធិប្រជាធិបតេយ្យ។

**ឧប សៅ សន្ធា** **គំនិត** **៣ មីនា ២០២០**